long beach unified school district

# ដំណឹងថ្មីៗពីការលូតលាស់

# ការចូលរួម * ស្នាដៃ * សុខុមាលភាព

ខែកុម្ភៈ២០១៩

មាតាបិតា សិស្ស និងបុគ្គលិកសាលាចាប់ផ្តើមធ្វើការស្ទង់មតិនៅក្នុងខែកុម្ភៈ ហើយសិស្សនឹងចាប់ផ្តើមធ្វើតែស្តថ្មីរបស់រដ្ឋនៅក្នុងខែមិនា។ ការស្ទង់មតិនិងតែស្ត ជាផ្នែកមួយនៃប្រព័ន្ធទំនួលខុសត្រូវថ្មីនិងប្រសើរជាងមុនសម្រាប់សាលារៀនយើង នឹងស្ទង់ប្រមាណមើលថាតើសិស្សរៀនបានលទ្ធផលយ៉ាងណា ហើយថាតើសាលារៀនមានគុណភាពយ៉ាងណា ដោយស្ទង់វាស់មើលនូវ ការចូលរួម ស្នាដៃ និងសុខុមាលភាព។ ការខិតខំខ្នែងមួយចំនួនកំពុងត្រូវបានអនុវត្តដើម្បីគាំទ្រសិស្សនៅក្នុងប្រព័ន្ធថ្មីនេះ។

**មាតាបិតាត្រូវបានលើកទឹកចិត្តឲ្យតាមដានការលូតលាស់របស់កូនគាត់ខណៈដែលប្រព័ន្ធថ្មីនេះត្រូវបានដាក់អនុវត្ត។ ក៏ប៉ុន្តែសូមចាំថា ស្តង់ដាសាមញ្ញលើមុខវិជ្ជាស្នូលថ្មីដែលមានភាពតឹងតែងជាងការស្ទង់ប្រមាណថ្មី ហើយនិងវិធានការណ៍ទំនួលខុសត្រូវថ្មីជាតំណាងនៃការក្រិតឲ្យតាមខ្នាតមួយសារឡើងវិញ ដែលអាចធ្វើឲ្យមានការយល់ឃើញថាស្នាដៃរបស់សិស្សមានការចុះអន់ថយ។ សូមកុំមានការព្រួយបារម្ភណ៏បើឃើញមានការចុះអន់ថយដំបូងនូវលទ្ធផលតែស្តរបស់កូន។ ខណៈដែលសេចក្តីរំពឹងត្រូវបានដាក់ខ្ពស់ជាងមុន វានឹងចំណាយពេលច្រើនដើម្បីឲ្យការបង្ហាត់បង្រៀននិងការរៀនសូត្រសម្របទៅតាមសេចក្តីរំពឹងនោះ។**

## ប្រព័ន្ធវាយតម្លៃលើគ្រូបង្រៀននិងនាយកសាលា-*តាមរបៀបរបស់ឡុងប៊ីច*

នៅក្នុងរដូវក្តៅ២០១៨ ក្រសួងអប់រំចាប់ផ្តើមដាក់អនុវត្តប្រព័ន្ធថ្មីពីរដើម្បីគាំទ្រសិស្សនិងការលូតលាស់របស់សាលា។ ប្រព័ន្ធវាយតម្លៃគ្រូបង្រៀននិងនាយកសាលាដែលទើបបង្កើតឡើងថ្មីនេះ បានដាក់អនុវត្តបន្ទាប់ពីការស្រាវជ្រាវសិក្សា សហការនិងរៀបគ្រោងឡើងជាច្រើនឆ្នាំ។ ខណៈដែលប្រព័ន្ធទាំងនេះគឺសម្រាប់ក្រុមបុគ្គលិកសាលាពីរផ្សេងពីគ្នា(គឺគ្រូបង្រៀនហើយនិងអភិបាលសាលា) វាត្រូវបានបង្កើតឡើងដើម្បីគាំទ្រគ្នា បង្កើតជាភាសាសាមញ្ញមួយក្នុងចំណោមបុគ្គលិកសាលា នៅក្នុងពេលដែលពួកគេធ្វើការដើម្បីលើកស្ទួយដល់ការលូតលាស់របស់សិស្ស។

ប្រព័ន្ធវាយតម្លៃគ្រូបង្រៀននៅក្នុងក្រសួងអប់រំឡុងប៊ីច គឺយោងទៅតាមស្តង់ដារដ្ឋកាលីហ្វ័រនីញ៉ាសំរាប់ការបង្ហាត់បង្រៀន (California Standards for the Teaching Profession)។ ស្តង់ដាដែលមានមូលដ្ឋានពីការស្រាវជ្រាវនេះចែងនូវការប្រតិបត្តិនៅក្នុងថ្នាក់រៀនដែលធ្លាប់បង្ហាញឲ្យឃើញថាមានឥទ្ធិពលវិជ្ជមានលើជោគជ័យរបស់សិស្ស។ ប្រព័ន្ធវាយតម្លៃគ្រូបង្រៀនប្រើស្តង់ដាមួយចំនួនដើម្បីជួយឲ្យគ្រូទាំងអស់សញ្ជឹងយកចិត្តទុកដាក់ទៅលើអ្វីដែលមានប្រយោជន៏ជាងគេដល់សិស្ស។ ប្រព័ន្ធនេះផ្តល់ឱកាសដល់នាយកសាលាឲ្យសង្កេតមើលសកម្មភាពរបស់គ្រូបង្រៀន ប្រមូលភស្តុតាងនៃការបង្ហាត់បង្រៀននិងការរៀនចេះពេលនៅក្នុងថ្នាក់ ហើយដើម្បីផ្តល់យោបល់ដល់គ្រូបង្រៀនដោយរបៀបគាំទ្រដើម្បីជួយធ្វើឲ្យប្រសើរឡើងដល់ការបង្ហាត់បង្រៀនរបស់គ្រូ។

ប្រព័ន្ធវាយតម្លៃនាយកសាលានៅក្នុងក្រសួងអប់រំឡុងប៊ីច គឺយោងទៅតាមការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសនិងតាមស្តង់ដាលើកត្តាកំរិតសាលានិងសញ្ញាចង្អុលបង្ហាញដែលបានបង្ហាញឲ្យឃើញថាមានឥទ្ធិពលច្រើនជាងគេលើជោគជ័យរបស់សិស្ស។ នៅក្នុងក្រសួងអប់រំឡុងប៊ីច LBUSD នាយកសាលានីមួយៗចូលរួមក្នុងការវាយតម្លៃជារៀងរាល់ឆ្នាំ ដែលមានរួមទាំងការដាក់គោលដៅសាលានិងភាពនៃការដឹកនាំ(យោងតាមគុណភាពនិងសេចក្តីចាំបាច់លើអ្វីមួយរបស់សាលា) ការចូលមើលក្នុងថ្នាក់រៀនដើម្បីសម្រេចមើលគុណភាពនៃការបង្ហាត់បង្រៀននិងការ រៀនសូត្រ ការចែករំលែកនូវភស្តុតាងនៃការលូតលាស់ដែលអ្នកដឹកនាំសិស្ស និងគ្រូបង្រៀនកំពុងធ្វើដើម្បីឲ្យដូចគោលដៅ ហើយនិងការវាយតម្លៃផ្តាច់ព្រ័តដែលមានរួមបញ្ចូលនូវទិន្នន័យនៃការលូតលាស់របស់សិស្ស។

ប្រព័ន្ធនៃការវាយតម្លៃថ្មីទាំងពីរនេះមានតម្លៃ៤កំរិត គឺល្អលើសគេ មានប្រសិទ្ធិភាព កំពុងលូតលាស់ និងមិនពេញ ចិត្ត។ ការយកចិត្តទុកដាក់ដ៏សមើ្បមត្រូវបានចំណាយទៅលើការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬការហ្វឹកហ្វឺនដែលចាំបាច់ដើម្បីបញ្ជាក់ថាគ្រូបង្រៀននិងនាយកសាលាម្នាក់ៗយល់អំពីសេចក្តីរំពឹងថ្មីៗនៅក្នុងប្រព័ន្ធទាំងនេះហើយនិងការគាំទ្រផ្សេងៗដែលចាំបាច់សម្រាប់ឲ្យបុគ្គលិកបំពេញកិច្ចការឲ្យបានល្អ។ ប្រសិនបើលោកអ្នកមកទស្សនាសាលានៅឡុងប៊ីច វាមិនជាការអ្វីប្លែកទេបើលោកអ្នកឃើញ អភិបាលសាលាកំពុងសង្កេតមើលការបង្ហាត់បង្រៀននិងការរៀនសូត្រ ឬឃើញនាយកសាលាដើរនៅក្នុងសាលាឬនៅក្នុងថ្នាក់រៀនជាមួយអ្នកត្រួតពិនិត្យនាយកសាលា។ ប្រព័ន្ធទាំងនេះបានទទួលចំណាប់អារម្មណ៏ទូទាំងប្រទេសចំពោះការលើកស្ទួយដល់ការរៀនសូត្ររបស់គ្រូបង្រៀននិងអភិបាលសាលាខណៈដែលសញ្ជឹងយកចិត្តទុកដាក់ដល់ការលូតលាស់របស់សិស្ស។

## ផែនការណ៏ត្រួតត្រានិងទំនួលខុសត្រូវ

រូបមន្តត្រួតត្រាលើថវិការសាលា(LCFF) ផ្តល់ឲ្យសាលានូវលទ្ធភាពច្រើនជាងមុនក្នុងការប្រើប្រាសថវិការរដ្ឋយោងទៅតាមសេចក្តីចាំបាច់របស់សិស្ស។ រូបមន្តថវិការនេះតម្រូវឲ្យក្រសួងអប់រំបង្កើតនូវផែនការណ៏ត្រួតត្រានិងទំនួលខុសត្រូវ (LCAP)

ដែលមានរាយរាប់ អាទិភាពចំណាយនិងគោលដៅស្នាដៃដើម្បីបញ្ជាក់ថាធនធានត្រូវបានប្រើប្រាសដោយមានប្រសិទ្ធិភាព។

ផែនការណ៏របស់ LBUSD គាំទ្រការលូតលាស់របស់សិស្សជាច្រើនផ្លូវ។ ផែនការណ៏មានរួមនូវកម្មវិធីផ្សេងៗដែលផ្តល់ប្រយោជន៍ ជាក់ស្តែងសម្រាប់សិស្សយើងទាំងអស់ ជាពិសេសសិស្សដែលមានការចាំបាច់ច្រើនជាងគេ។ ឧទាហរណ៏ ផែនការណ៏នេះពង្រីកការអប់រំផ្តល់ឱកាសពីថ្នាក់មត្តេយ្យដល់ទី១២ ការសិក្សាបណ្ណាល័យ សេវាកម្មពេទ្យនៅសាលានិងបច្ចេកវិទ្យា ព្រមទាំងកម្មវិធីតន្ត្រីនៅសាលាបឋមសិក្សាហើយនិងការគាំទ្រផ្សេងៗច្រើនយ៉ាងទៀតនៅសាលាមធ្យមសិក្សា។ ចំណែកនៅឯសាលាវិទ្យាល័យវិញផែនការណ៏ នេះអនុញ្ញាតឲ្យសិស្សរៀនថ្នាក់សម្រាប់ត្រៀមបំរុងប្រឡង SAT និងការប្រឡងថ្នាក់កំរិតមហាឬសាកលវិទ្យាល័យដោយមិនគិតថ្លៃ ដែលជួយសន្សំប្រាក់រាប់រយដុល្លារដល់គ្រួសារសិស្ស។

ផែនការណ៏របស់ LBUSD ឆ្លើយតបទៅនឹងចំណុចផ្សេងៗដែលជាអាទិភាពរបស់រដ្ឋខណៈដែលបំពេញនូវគោលដៅរបស់ក្រសួងអប់រំផងដែរ។ វារួមបញ្ចូលលទ្ធផលពីការស្ទង់ប្រមាណ Smarter Balanced ការស្ទង់មតិរបស់សិស្ស មាតាបិតានិងបុគ្គលិក ហើយនិងវិធានការណ៏ទំនួលខុសត្រូវជាច្រើនផ្សេងទៀត។ ទិន្នន័យរបស់សាលារៀននីមួយៗមាននៅក្នុងគេហទំព័រ lbschools.net នៅក្នុង បញ្ជីលេខរៀងអក្សរ A-Z ពាក្យ LCAP បន្ទាប់មកគឺពាក្យ LCAP District & School Data ។ របាយការណ៏ទាំងនេះជួយមហាជន ឲ្យឃើញនូវធនធានដែលឧបត្ថមដោយប្រាក់ពន្ធដា កំពុងត្រូវបានប្រើប្រាសដោយមានទំនួលខុសត្រូវដើម្បីផ្តល់ឲ្យសិស្សនូវអនាគតដ៏ត្រចះត្រចង់។

## គំរោងការណ៏ចំណាយសម្រាប់បន្តធ្វើឲ្យមានការប្រសើរឡើង (CIE)

ចាប់តាំងពីការដាក់អនុវត្តនូវ LCAP មក នាយកសាលាបានពិនិត្យមើលឡើងវិញនូវប្រព័ន្ធនៅសាលារៀនរបស់ពួកគាត់ដែលបញ្ចូលរួមដៃគូទាំងអស់(គ្រូបង្រៀន មាតាបិតា សហគម)នៅក្នុងនីតិវិធីចាត់ចែងថវិកា។ ដើម្បីគាំទ្រដល់សិស្សឲ្យមានប្រសិទ្ធិភាពបំផុត ការរៀបចំចាត់ចែងថវិកាត្រូវការនីតិវិធីនៃការចូលរួម យុទ្ធសាស្ត្រ និងការពិនិត្យមើលឡើងវិញ។

នៅក្នុង LBUSD យន្តការមួយដែលប្រើសម្រាប់បញ្ជាក់ថាថវិកាសំរេចរបស់សាលាប្រើសំរាប់គាំទ្រដល់ការលូតលាស់របស់សិស្ស គឺយន្តការចំណាយសម្រាប់បន្តធ្វើឲ្យមានការប្រសើរឡើង (CIE)។ អ្នកដឹកនាំសាលាបានទទួលគោលការណ៏ណែនាំសម្រាប់សំរេចមើលថាអ្វីខ្លះជាថវិកាដែលអនុញ្ញាតឲ្យប្រើប្រាស ដាក់អាទិភាពយោងទៅតាមសេចក្តីចាំបាច់របស់សិស្សនិងបុគ្គលិកសាលា ហើយនិងរបៀបសំរាប់ស្ទង់វាស់មើលគុណភាពនៃផែនការណ៏របស់ពួកគេ។ នៅពេលណាសាលាបានសំរេចឃើញថាអ្វីដែលគេជឿជាសកម្មភាព ប្រព័ន្ធ ឬយុទ្ធសាស្ត្រសម្រាប់គាំទ្រសិស្សនៅសាលារបស់ពួកគេ ព័ត៌មាននេះនឹងដាក់បញ្ចូលទៅក្នុងរូបមន្តផែនការណ៏។ ផែនការណ៏របស់សាលាបន្ទាប់មកនឹងត្រូវពិនិត្យមើលដោយបុគ្គលិកទទួលបន្ទុកថវិកាដែលមានរួមទាំងអ្នកដឹកនាំក្នុងក្រសួងអប់រំ។ ដោយមានដំណើរការច្រើនគន្លាក់យ៉ាងនេះ CIE អាចបញ្ជាក់នូវភាពច្បាស់លាស់និងការធ្វើទំនាក់ទំនងស្របគ្នាជាមួយគោលដៅរបស់ក្រសួងអប់រំ។ ផែនការណ៏ CIE សំរាប់សាលារៀននីមួយៗមាននៅ lbschools.net ជាមួយពាក្យ Continuous Improvement Expenditure Plans នៅក្នុងបញ្ជីលេខរៀងអក្សរ A-Z ។

## ការសុំលើកលែងអនុវត្តតាមច្បាប់របស់សហព័ន្ធ

ផែនការណ៏របស់ LBUSD ត្រូវបានពង្រឹងដោយការសុំលើកលែងអនុវត្តតាមច្បាប់របស់សហព័ន្ធ គឺច្បាប់ No Child Left Behind rules។ ស្រដៀងគ្នាទៅនឹង LCFF របស់រដ្ឋដែរ ការលើកលែងពីសហព័ន្ធនេះផ្តល់ឲ្យសាលារៀននូវភាពធូរស្រាលច្រើនជាងមុនក្នុងការប្រើថវិការបស់សហព័ន្ធ យោងទៅតាមសេចក្តីចាំបាច់របស់សិស្ស។ ភាពធូរស្រាលនេះកើតមកពីគណៈកម្មាធិការ LBUSD ឲ្យប្រើប្រព័ន្ធធ្វើឲ្យប្រសើរឡើងគុណភាពសាលា ដែលជាគំរូទំនួលខុសត្រូវមួយភ្ជាប់គ្នាជាមួយគោលគំនិតទាំងអស់ដែលបានពណ៌នាមកខាងលើ។

គំរូនេះមានរួមទាំងកិច្ចការរបស់យើងលើស្តង់ដាសាមញ្ញលើមុខវិជ្ជាស្នូលនិងការវាយតម្លៃបុគ្គលិកសាលា។ គំរូនេះក៏តាមដានមើលវិធានការណ៏ទំនួលខុសត្រូវដូចគ្នាដែលយើងមាននៅក្នុងផែនការណ៏យើងផងដែរ។ សំខាន់ជាងនេះ វាបង្កើតរបៀបថ្មីមួយដើម្បីធ្វើឲ្យប្រសើរឡើងដល់សាលារៀនដែលត្រូវការជំនួយច្រើនជាងគេ-ជាវិធីមួយដែលផ្តល់ការគាំទ្របន្ថែម ជាជាងដាក់ទោសដល់សាលាទាំងនោះ។

នៅក្រោមគំរូនេះ សាលារៀនដែលប្រព្រឹត្តមិនបានស្មើដូចគោលដៅរបស់ខ្លួន ទទួលការហ្វឹកហ្វឺនវិជ្ជាជីវៈសំរាប់គ្រូបង្រៀនហើយនិងធនធានគាំទ្រផ្នែកសង្គមពីដៃគូរបស់ក្រសួងអប់រំ។ សាលារៀនដែលត្រូវការជំនួយច្រើនជាងគេបានទទួលជំនួយផ្ទាល់ពីអ្នកអប់រំដែលបានទទួលជោគជ័យនៅក្រោមកាលៈទេសៈស្រដៀងគ្នានេះដែរ។ គោលគំនិតគឺថា នៅពេលសាលាណាមួយរៀនពីគ្នាទៅវិញទៅមក ពួកគេនឹងរៀបត្រៀមសិស្សបានប្រសើរជាងសំរាប់ជោគជ័យនៅមហាវិទ្យាល័យនិងអាជីព។ ព័ត៌មានថែមទៀតអំពីប្រព័ន្ធនេះមាននៅក្នុងគេហទំព័រ coredistricts.org ។